សុន្ទរកថា របស់

**លោកស្រី Kristin Parco**

**ប្រធានបេសកកម្ម អង្គការទេសន្តរប្រវេសន៍អន្តរជាតិ**

តំណាងឲ្យក្រុមការងារទទួលបន្ទុកផ្នែកសុខភាព និងកិច្ចគាំពារ

ពលករចំណាកស្រុក ដែលធ្វើមាតុភូមិនិវត្តន៍

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

ក្រសួងមហាផ្ទៃ

---

*សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមេត្រី!*

អរុណសួស្តី

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ជូ ប៊ុនអេង ដែលបានផ្តល់ព័ត៌មានសង្ខេបទាក់ទងនឹងស្ថានភាពនៃពលករចំណាកស្រុកវិលត្រឡប់មកពីប្រទេសថៃ និងការដឹកនាំរបស់លោកជំទាវ ក្នុងការធានាឱ្យមានកិច្ចគាំពារ និងការគោរពសិទ្ធិរបស់ពលករចំណាកស្រុក ជាអាទិភាពនៅក្នុងវិធានការឆ្លើយតប សម្រាប់ការវិលត្រឡប់នៃពលករចំណាកស្រុក។

ពលករចំណាកស្រុក និងសហគមន៍ដែលពួកគាត់រស់នៅ មានភាពងាយរងគ្រោះជាខ្លាំង និងរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ព្រោះតែហេតុផលមួយចំនួនៈ ពួកគេងាយរងគ្រោះចំពោះការឆ្លងរោគ ដោយសារតែលក្ខខណ្ឌនៃការរស់នៅ និងប្រកបរបរទទួលទានរបស់ពួកគេ។ គោលគំនិត ដូចជា ការរក្សាគម្លាតរវាងបុគ្គល និងការរក្សាគម្លាតក្នុងសង្គម ការបង្កើនអនាម័យ និងការដាក់ខ្លួននៅដាច់ដោយឡែក មិនអាចធ្វើទៅបានឡើយ សម្រាប់ពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ ដោយសារពួកគេអាចរស់នៅក្នុងទីកន្លែងតូចចង្អៀត និងលក្ខខណ្ឌនៃការរស់នៅដែលមានគ្នាច្រើន។ ពួកគេមិនបានទទួលកិច្ចការពារគ្រប់គ្រាន់ឡើយ នៅតាមកន្លែងធ្វើការ និងអាចពុំមានធនធាន ឬលទ្ធភាព ដើម្បីកាត់បន្ថយការប៉ះពាល់ជាមួយអ្នកដទៃឡើយ។

ពលករចំណាកស្រុក ក៏អាចប្រឈមហានិភ័យនៃការចម្លងរោគផងដែរ នៅក្នុងអំឡុងពេលសំចត និងនៅពេលពួកគេស្ថិតនៅក្នុងការផ្លាស់ទី ដោយពួកគេតែងមានការប៉ះពាល់ជាមួយមនុស្សជាច្រើន។ ក្នុងបរិបទជាច្រើន ពលករចំណាកស្រុក អាចត្រូវផាត់ចេញពីប្រព័ន្ធសុខាភិបាល ឬមានឧបសគ្គបន្ថែមទៀត ដូចជា ថ្លៃចំណាយលើការថែទាំសុខភាព កង្វះការធានារ៉ាប់រង ឧបសគ្គខាងភាសា និងវប្បធម៌ប្រពៃណីផងដែរ។ ដូច្នេះ ពលករចំណាកស្រុកទាំងនោះ ដែលពិតជាត្រូវធ្វើតេស្ត និងព្យាបាល អាចពុំបានទទួលសេវាកម្មចាំបាច់ទាំងនេះឡើយ ដែលធ្វើឱ្យពួកគេ

ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរជាងប្រជាពលរដ្ឋតាមមូលដ្ឋាន។ ផលប៉ះពាល់សង្គម-សេដ្ឋកិច្ច មកលើពលករចំណាកស្រុក អាចមានកម្រិតធ្ងន់ធ្ងរ ដោយសារតែប្រភេទឧស្សាហកម្មដែលជាកន្លែងពួកគេធ្វើការ ទំនងនឹងត្រូវបិទទ្វារជាបណ្តោះអាសន្ន ពួកគេមិនបានទទួលការគិតគូរឡើយ នៅក្នុងវិធានការខាងសេដ្ឋកិច្ចសម្រាប់កាត់បន្ថយផលប៉ះពាល់ ហើយក៏ពុំមានយន្តការគាំពារសង្គមសម្រាប់ពួកគេផងដែរ។ ស្ថានភាពនេះជម្រុញឱ្យមានចំណាកស្រុកកាន់តែច្រើន ដោយសារពលករចំណាកស្រុក ចាំបាច់ត្រូវចាកចេញពីប្រទេស និងទីកន្លែងគោលដៅ ដោយសារតែការបាត់បង់ការងារ និងការតម្រូវឱ្យវិលត្រឡប់មកស្រុកកំណើតវិញ ដែលនេះជាបទពិសោធន៍កម្ពុជាបានជួបប្រទះក្នុងរយៈពេលប៉ុន្មានសប្តាហ៍កន្លងទៅ ដោយមានពលករខ្មែរចំណាកស្រុកច្រើនជាង ៧០.០០០ នាក់ ដែលធ្វើការក្នុងប្រទេសថៃ បានវិលត្រឡប់មកផ្ទះវិញ ហើយប្រការនេះនឹងធ្វើឱ្យប៉ះពាល់ដល់គ្រួសារ និងសហគមន៍របស់ពួកគេដោយសារ តែការបាត់បង់ប្រាក់ចំណូលដែលពួកគេធ្លាប់បានផ្ញើមកផ្ទះ។ យើងក៏កំពុងឃើញផលប៉ះពាល់ចំពោះអ្នកឆ្លងដែនទាំងនោះផងដែរ ដោយសារកំណើននៃការមាក់ងាយ និងការរើសអើងចំពោះពលករចំណាកស្រុកទាំងនេះមិនត្រឹមតែក្នុងតំបន់ជាគោលដៅធ្វើការរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងអំឡុងពេលធ្វើដំណើរ/សំចត និងសូម្បីពួកគេមកដល់ផ្ទះហើយក៏ដោយ ដោយសារតែការភ័យខ្លាចការឆ្លងជំងឺកូវីដ-១៩។ ប្រសិនបើពុំមានការដោះស្រាយស្ថានភាពនេះទេ កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសនានាក្នុងការគ្រប់គ្រងការចម្លងរោគ និងការកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ នឹងត្រូវបរាជ័យ។

ដោយសារតែប្រការទាំងនេះ និងកត្តាដទៃទៀត អង្គការ WHO, IOM, UNICEF, UNFPA, UNAIDS, UN Women, UNOPS និង OHCHR ទទួលស្គាល់ថា ប្រការដែលមានសារៈសំខាន់ជាសារវន្ត គឺមិនត្រឹមតែពលករចំណាកស្រុក ជនភៀសខ្លួន និងពលរដ្ឋដែលត្រូវផ្លាស់ទីកន្លែងរស់នៅប៉ុណ្ណោះទេ ដែលត្រូវតែបានទទួលការយកចិត្តទុកដាក់នៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនៅកម្រិតជាតិ ប៉ុន្តែភាពចាំបាច់នេះមានច្រើនលើសពីនេះទៅទៀត ដោយរាប់បញ្ចូល ទាំងក្រុមប្រជាពលរដ្ឋងាយរងគ្រោះ និងទន់ខ្សោយ ដូចជា ស្ត្រី ស្ត្រីមានផ្ទៃពោះ កុមារ យុវជន មនុស្សចាស់ អ្នកផ្ទុកមេរោគអេដស៍ និងរោគរបេង និងជនពិការផងដែរ។ អាស្រ័យហេតុនេះ ការពិចារណា និងចំណាត់ការយ៉ាងសកម្ម ក៏ ត្រូវតែបានធ្វើឡើងផងដែរ ដើម្បីផ្តល់ឱ្យ និងរួមបញ្ចូលក្រុមប្រជាពលរដ្ឋទាំងនេះ សម្រាប់ការត្រៀមបង្ការ ការឆ្លើយតប និងការកាត់បន្ថយផលប៉ះពាល់។

ក្រោមការណែនាំរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក និងស្របជាមួយផែនការមេរបស់កម្ពុជា អង្គការសហប្រជាជាតិមានការប្តេជ្ញា ផ្តល់ការគាំទ្រនៅក្នុងការទប់ស្កាត់ការចម្លង និងកាត់បន្ថយជំងឺធ្ងន់ធ្ងរ និងការបាត់បង់ជីវិតឱ្យនៅក្នុងកម្រិតអប្បរមា ជួយធានានូវវត្តមាន និងការត្រៀមលក្ខណៈសម្រាប់សេវាសំខាន់ៗ និងកាត់បន្ថយផលប៉ះពាល់ឱ្យនៅកម្រិតអប្បរមា តាមរយៈវិធានការឆ្លើយតបពហុវិស័យ ដើម្បីគាំទ្រដល់វិធានការក្នុងវិស័យសុខភាពសាធារណៈ វិស័យសង្គម និងសេដ្ឋកិច្ចជារួម។ អាទិភាពទាំងនេះ នឹងធ្វើឡើងតាមរយៈ៖

1. **ការបង្កលក្ខណៈសម្រាប់ការទទួលបានដោយសមធម៌នូវសេវាសុខភាព និងគ្មានការរើសអើង ចំពោះប្រជាពលរដ្ឋងាយរងគ្រោះ និងទន់ខ្សោយ** ដោយតភ្ជាប់សេវាកម្មសុខភាព និងសង្គម និងការបញ្ជ្រាបវិធានការ

កាត់បន្ថយហានិភ័យនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ កិច្ចគាំពារកុមារ ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងចិត្តវិទ្យា-សង្គម (MHPSS) ការចូលរួមរបស់សហគមន៍ និងការពង្រឹងកិច្ចអន្តរាគមន៍កាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើសេវាសុខាភិបាល និងសេវាសង្គម នៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីសម្រួលដល់ការទទួលបាន និងការផ្តល់សេវាសុខភាព និងសេវាសង្គម ជាមួយវិធានការឆ្លើយតបចម្រុះ ដែលមានការសម្របសម្រួលរវាងគ្នា និងឆ្លើយតបទៅនឹងជំងឺកូវីដ-១៩។

2. **គាំទ្រឱ្យមានការពិចារណានៅក្នុងអភិក្រមរដ្ឋាភិបាល និងសង្គមទាំងមូល និងភាពជាដៃគូ នូវការត្រៀមបង្ការ ការទប់ស្កាត់ និងការត្រួតពិនិត្យការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងចំណោមពលករចំណាកស្រុក និងសហគមន៍របស់ពួកគេ ក្នុងបរិបទនៃគោលនយោបាយ និងការសម្របសម្រួលទូទាំងរដ្ឋាភិបាល** រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលរួមទាំង ភ្នាក់ងារក្នុង និងក្រៅវិស័យសុខាភិបាល រួមទាំង សង្គមស៊ីវិលផងដែរ និងការឈានទៅសម្រេចបានវិសាលភាពគ្របដណ្តប់ជាសកលនៃសេវាសុខាភិបាល ដែលក្នុងនោះពលករចំណាកស្រុក និងពលរដ្ឋងាយរងគ្រោះ (ស្ត្រីមានផ្ទៃពោះ កុមារ មនុស្សចាស់ អ្នកដែលស្ថិតក្នុងស្ថានភាពជំងឺ ដូចជា រោគរបេង និងអេដស៍ និងជនពិការ) ត្រូវបានបញ្ចូលទៅក្នុងយន្តការ ដែលមានស្រាប់ ដូចជា ការទប់ស្កាត់ ការធ្វើតេស្ត ការទទួលបានព័ត៌មាន ការព្យាបាល និងការពង្រឹងយន្តការបញ្ជូន។

សូមសម្តេច ឯកឧត្តម លោកជំទាវ អនុញ្ញាតឱ្យនាងខ្ញុំសំដែងនូវការកោតសរសើរដោយស្មោះស្ម័គ្រ ចំពោះថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល រួមទាំងក្រសួងផ្សេងទៀត និងនាយកដ្ឋានទាំងអស់ ដែលបានគ្រប់គ្រងការធ្វើមាតុភូមិនិវត្តន៍នៃពលករចំណាកស្រុកជាចំនួនច្រើន និងការគ្រប់គ្រងជំងឺកូវីដ-១៩ តាមរយៈអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ខេត្ត និងសូមថ្លែងអំណរគុណផងដែរចំពោះការជឿទុកចិត្តលើអង្គការសហប្រជាជាតិ ក្នុងការធ្វើការជាមួយសម្តេច ឯកឧត្តម លោកជំទាវ ដើម្បីជួយប្រជាពលរដ្ឋកម្ពុជានៅក្នុងដំណាក់កាលដ៏សំខាន់នេះ។

វីរុសនេះ មិនរើសអើង ឬ បង្ហាញភាពខុសគ្នារវាងជនចំណាកស្រុក ឬ ជនមិនចំណាកស្រុកឡើយ អាស្រ័យហេតុនេះ ការឆ្លើយតបរបស់យើង មិនត្រូវផ្តោតតែលើក្រុមណាតែមួយនោះទេ។ យើងទាំងអស់គ្នាស្ថិតនៅក្នុងស្ថានភាពនេះជាមួយគ្នា ដូច្នេះប្រការសំខាន់ជាសារវន្តគឺ មិនត្រូវទុកនណារម្នាក់ចោលឡើយ ហើយត្រូវកំចាត់រាល់ឧបសគ្គដែលអាចមានចំពោះពលករចំណាកស្រុក និងសហគមន៍របស់ពួកគាត់ នៅក្នុងកិច្ចប្រឹងប្រែងរួមគ្នា ក្នុងការប្រយុទ្ធប្រឆាំងកូវីដ-១៩។

សូមអរគុណសម្តេច ឯកឧត្តម លោកជំទាវ!